គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ឥណទានពលរដ្ឋរុងរឿង អិលធីឌី

INTEAN POALROATH RONGROEURNG LTD

# របាយការណ៍ប្រចាំឆ្នាំ ២០២៣



# តារាងមាតិកា


| | |
|---|---|
| មាតិកា | ២ |
| ទស្សនវិស័យ បេសកកម្ម និងតម្លៃស្នូល | ៣ |
| ប្រវត្តិគ្រឹះស្ថាន | ៤ |
| សាររបស់ប្រធានក្រុមប្រឹក្សាភិបាល | ៥ |
| សាររបស់នាយិកាប្រតិបត្តិ | ៦ |
| ក្រុមប្រឹក្សាភិបាល | ៧ |
| គណៈគ្រប់គ្រងក្រុមហ៊ុន | ៨ |
| ភាគទុនិក និងវិនិយោគិន | ១០ |
| អង្គការលេខ | ១២ |
| រចនាសម្ព័ន្ធសាខា | ១៣ |
| អតិថិជនគោលដៅ និងផលិតផល | ១៤ |
| លទ្ធផលការងារឆ្នាំ២០២៣ | ១៦ |
| ទិន្នន័យសំខាន់ៗ | ១៧ |
| លទ្ធផលការងារ | ១៨ |
| បទពិសោធន៍របស់អតិថិជន | ២២ |
| សវនកម្មផ្ទៃក្នុង និងការត្រួតពិនិត្យ | ២៤ |
| បុគ្គលិក និងការកសាងសមត្ថភាព | ២៥ |
| ទំនួលខុសត្រូវរបស់ ឥណទានពលរដ្ឋរុងរឿង | ២៧ |
| ទំនួលខុសត្រូវសង្គមរបស់អាយភីអា | ២៨ |
| របាយការណ៍បង់ពន្ធ | ២៩ |
| សម្រង់របាយការណ៍សវនកម្មហិរញ្ញវត្ថុឆ្នាំ២០២៣ | ៣០ |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ៣១ |
| របាយការណ៍របស់សវនករឯករាជ្យ | ៣៤ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៣៧ |
| របាយការណ៍ចំណូលលម្អិត | ៣៨ |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធន | ៣៩ |
| របាយការណ៍លំហូរទឹកប្រាក់ | ៤០ |
| ព័ត៌មានទំនាក់ទំនង | ៤១ |
| បណ្ដាញសាខា | ៤២ |
| អាសយដ្ឋានសាខាខេត្ត | ៤៣ |


២០២៣



# ទស្សនវិស័យ

## បេសកកម្ម និងតម្លៃស្នូល

### ទស្សនវិស័យ

ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កម្ពុជា បម្រើវិស័យកសិកម្មឈានមុខគេ។

### បេសកកម្ម

ផ្តល់នូវសេវាហិរញ្ញវត្ថុ ងាយស្រួល ស្របទៅតាមអាជីវកម្មដែលពាក់ព័ន្ធនឹង កសិកម្ម ដើម្បីធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌសេដ្ឋកិច្ចរបស់កសិករ ដោយធានាបាននូវការរីកចម្រើនដោយមាននិរន្តភាពរបស់គ្រឹះស្ថាន។

### គុណតម្លៃ

- ស្មោះត្រង់ និងសុចរិត
- ទទួលខុសត្រូវខ្ពស់
- ការបំពេញការងារជាក្រុម
- សេចក្តីថ្លៃថ្នូ និងការគោរព

# ប្រវត្តិគ្រឹះស្ថាន

**២០២១**

ស្ថាប័នទទួលបានវិញ្ញាបនបត្រអនុលោមភាពតាមច្បាប់សារពើពន្ធមាស ពីអគ្គនាយកដ្ឋានពន្ធដារ ដែលមានសុពលភាពសម្រាប់ឆ្នាំ ២០២១-២០២២។

**២០២០**

គ្រឹះស្ថានបានរងផលប៉ះពាល់ពី ការឆ្លងរីករាលដាលនៃជម្ងឺ កូវីដ ១៩ ដែលទាមទារអោយមានការប្រឹងប្រែង អត់ធ្មត់ និងពេលវេលា ដើម្បីស្តារស្ថានភាពអោយប្រសើរឡើងវិញ។

**២០១៧**

គ្រឹះស្ថានបានរងផលប៉ះពាល់ពី ការថយចុះនៃផលបត្រឥណទាន ដែលជះឥទ្ធិពលពីការកំហិតពិដានការប្រាក់របស់ ធនាគារជាតិនៃកម្ពុជា។

**២០១៥**

Leopard Cambodia Fund បានចាកចេញពីភាគទុនិក តាមរយៈការលក់ភាគហ៊ុនទាំងមូលរបស់ខ្លួនឲ្យលោកឧកញ៉ា ភួ ពុយ។

**២០១១**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានពលរដ្ឋរុងរឿងមានភាពល្អប្រសើរឡើងវិញបន្ទាប់ពីវិបត្តិសេដ្ឋកិច្ចជាមួយការពង្រឹងដំណើរការផ្ទៃក្នុងការបន្តអភិវឌ្ឍន៍ និងវិវត្តន៍ខ្លួនជាគ្រឹះស្ថានមួយដែលទទួលបានប្រាក់ចំណេញច្រើនក្នុងចំណោមគ្រឹះស្ថានផ្សេងៗទៀត។

**២០១០**

លោកស្រី ហៅ ស៊ីមន បានចាកចេញពីភាគទុនិក ហើយ Leopard Cambodia Fund បានក្លាយជាភាគទុនិកភាគតិចតាមរយៈក្រុមហ៊ុន IPR ( KH ) ដែលមានមូលដ្ឋាននៅហុងកុង។

**២០០៨**

ឥណទានពលរដ្ឋរុងរឿង ទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពី ធនាគារជាតិនៃកម្ពុជា។

**២០០៥**

អង្គភាពនេះបានប្រែក្លាយទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ហើយបានចុះបញ្ជីជាផ្លូវការជាមួយក្រសួងពាណិជ្ជកម្មក្រោមឈ្មោះ “ឥណទានពលរដ្ឋរុងរឿង អិលធីឌី” ដែលមានលេខចុះបញ្ជី Co.7896KH/2005។ ក្រុមហ៊ុនក៏ទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលេខ MF014 ពី ធនាគារជាតិនៃកម្ពុជា (NBC)។

**២០០៣**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានពលរដ្ឋរុងរឿងបង្កើតឡើងក្នុងនាមជាផ្នែកឥណទាននៃសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា។

# សាររបស់
# ប្រធានក្រុមប្រឹក្សាភិបាល



**លោកឧកញ៉ា ភួ ពុយ**
**ប្រធានក្រុមប្រឹក្សាភិបាល**

ឆ្នាំ២០២៣ បានបង្ហាញពីការបន្តងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក ខណៈមានបញ្ហាប្រឈមជាច្រើន បើទោះបីជាមានល្បឿនយឺត ក៏ដូចជាការឆ្លុះបញ្ចាំងនូវស្ថិរភាពនៃសេដ្ឋកិច្ចរបស់កម្ពុជា រួមទាំងស្ថិរភាពនៃប្រតិបត្តិការរបស់ អាយភីអា បើទោះបីជាមានការថយចុះបន្តិចក្តី។

ក្នុងឆ្នាំ២០២៣ កម្ពុជាសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ច ៥% ដែលទាបជាងអត្រា ៥.១% ក្នុងឆ្នាំ ២០២២ បន្តិច ដែលនេះជាលទ្ធផលបានមកដោយការនាំចេញដ៏រឹងមាំនៃផលិតផលមិនពាក់ព័ន្ធវិស័យកាត់ដេរ។ កំណើនសេដ្ឋកិច្ចនេះក៏បានចូលរួមដោយការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ និងការបង្កើនលំហូរ FDI ក្នុងប្រទេសផងដែរ។

ពិតប្រាកដណាស់ យើងបានដឹងអំពីការកើនឡើងនូវភាពតានតឹង នៃភូមិសាស្ត្រនយោបាយ និងការរឹតបន្តឹងយ៉ាងខ្លាំងក្លានៃគោលនយោបាយរូបិយវត្ថុនៅក្នុងប្រទេស ជឿនលឿនដែលក្នុងគោលបំណងគ្រប់គ្រងការកើនឡើងអតិផរណា ប៉ុន្តែទោះបីជាមានសម្ពាធពីកត្តាខាងក្រៅក៏ដោយការបន្តការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការត្រួតពិនិត្យយ៉ាងដិតដល់នូវហានិភ័យដែលអាចកើតមានចំពោះប្រព័ន្ធធនាគារទាំងមូល និងវិធីសាស្ត្រសកម្មក្នុងការកំណត់វិធានការប្រុងប្រយ័ត្នដើម្បីការពារស្ថិរភាពហិរញ្ញវត្ថុបានជួយរក្សា និងការពារប្រព័ន្ធធនាគាររបស់កម្ពុជាឱ្យបន្តមានភាពធន់។ យ៉ាងណាមិញ យើងក៏បានឃើញថាមានការធ្លាក់ចុះនៃកំណើនឥណទាន និងការកើនឡើងនៃហានិភ័យឥណទានសម្រាប់វិស័យទាំងមូល ទោះជាយ៉ាងណាក្តី អាយភីអា នឹងនៅតែប្រុងប្រយ័ត្ន និងបន្តផ្តល់មូលនិធិដើម្បីគាំទ្រការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយជំងឺរាតត្បាតកូវីដ១៩។

លទ្ធផលរបស់អាយភីអាក្នុងឆ្នាំ២០២៣ បានធ្លាក់ចុះបន្តិចបើប្រៀបធៀបទៅនឹងឆ្នាំមុន ប៉ុន្តែយើងនៅតែអាចរក្សាបាននូវភាពរឹងមាំ ទោះស្ថិតក្នុងកាលៈទេសៈបែបណាក៏ដោយ យើងអាចរក្សាបាននូវសាច់ប្រាក់ដ៏រឹងមាំ។ អាយភីអា នឹងនៅតែផ្តោតលើបេសកកម្មរបស់ខ្លួនឆ្ពោះទៅរកវិស័យកសិកម្មដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់កម្ពុជា។ ដើម្បីភាពរីកចម្រើននាពេលអនាគត អាយភីអា នឹងបន្តផ្តោតលើវិស័យកសិកម្មជាទីផ្សារសំខាន់ ដើម្បីពង្រីកផលប័ត្រឥណទានរបស់ខ្លួនបន្ថែមពីលើផ្នែកផ្សេងទៀត។

សំខាន់ជាងនេះទៅទៀត គំរូអាជីវកម្មដ៏ទូលំទូលាយរបស់យើងដែលផ្តោតលើខ្សែសង្វាក់កសិកម្មដោយ មានការចូលរួមពីដៃគូសហប្រតិបត្តិការបន្ថែមនៅតែមានសារៈសំខាន់។ ការរួមបញ្ចូលគ្នាតែមួយរបស់យើងនៃប្រាក់ចំណេញ អនុបាតកម្ចីទាប ការផ្តោតលើវិស័យកសិកម្ម និងការរួមចំណែកដល់សង្គមជាវិជ្ជមានចំពោះកសិករជនបទ អាចជួយបង្កើនភាពទាក់ទាញដល់វិនិយោគិន។ មិនតែប៉ុណ្ណោះរួមជាមួយនឹងជម្រើសផលិតផលកម្ចីច្រើនប្រភេទ យើងសង្ឃឹមថានឹងពង្រីកលទ្ធភាពរបស់យើងទៅកាន់មូលដ្ឋានអ្នកប្រើប្រាស់កាន់តែច្រើនឡើងដោយស្របទៅតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ អាយភីអា នឹងខិតខំបន្តសម្រេចបាននូវសុខភាពហិរញ្ញវត្ថុ និងការលូតលាស់ដែលមាននិរន្តភាព។

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរជាបន្តចំពោះសមាជិកក្រុមប្រឹក្សាភិបាល ដៃគូអាជីវកម្មរបស់យើង អតិថិជនដ៏មានតម្លៃរបស់យើង គណៈគ្រប់គ្រងប្រតិបត្តិ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃ អាយភីអា ចំពោះការប្តេជ្ញាចិត្ត និងការលះបង់ជាបន្តបន្ទាប់នាពេលកន្លងមក។

On behalf of the Board of Directors,



ឧកញ៉ា ភួ ពុយ
ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់
# នាយិកាប្រតិបត្តិ



**កញ្ញា ភួ សុវណ្ណច័ន្ទ**
**នាយិកាប្រតិបត្តិ**

សកម្មភាពសេដ្ឋកិច្ចក្នុងឆ្នាំ២០២៣ មានភាពយឺតជាងការរំពឹងទុក ដោយសារការជាប់គាំងនៃរចនាសម្ព័ន្ធ និងបញ្ហាពីកត្តាខាងក្រៅជាបន្តបន្ទាប់ នេះបើយោងតាមការធ្វើបច្ចុប្បន្នភាពសេដ្ឋកិច្ចរបស់ធនាគារពិភពលោកសម្រាប់កម្ពុជា។ ប្រទេសកម្ពុជាសម្រេចបាននូវអត្រាកំណើន GDP ៥% ទាបជាងអត្រា ៥.១% នៃឆ្នាំ២០២២ បន្តិច។ កំណើនឥណទានបានធ្លាក់ចុះពី ១៩% ក្នុងឆ្នាំ ២០២២ មកនៅត្រឹម ៤.២% ក្នុងឆ្នាំ ២០២៣ ជាមួយនឹងអត្រាការប្រាក់ខ្ពស់ កម្រិតបំណុលក៏កើនឡើង យ៉ាងណាមិញស្ថានភាពទាំងនេះបានបង្កើនការប្រុងប្រយ័ត្នរបស់ស្ថាប័នធនាគារ និងហិរញ្ញវត្ថុក្នុងការផ្តល់ប្រាក់កម្ចី។ ការកើនឡើងនៃប្រាក់កម្ចីមិនដំណើរការសម្រាប់វិស័យទាំងមូលក៏បណ្តាលឱ្យមានការព្រួយបារម្ភផងដែរ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពនេះបានដាស់តឿនអោយគូរប្រកួតប្រជែងក្នុងទីផ្សារទាំងមូលបង្កើនការប្រុងប្រយ័ត្នចំពោះការរីកលូតលាស់របស់ពួកគេ ហើយទន្ទឹមនឹងនោះ ការតម្រូវអោយប្រតិបត្តិតាមក្រមសីលធម៌របស់ BFI បានធានាថាធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់បម្រើអតិថិជនដោយភាពទទួលខុសត្រូវ និងប្រុងប្រយ័ត្នបន្ថែម។ ទន្ទឹមនឹងនេះ អតិផរណារបស់កម្ពុជាក៏បានធ្លាក់ចុះពី ៥.៤% ក្នុងឆ្នាំ ២០២២ មកត្រឹម ២.១% ក្នុងឆ្នាំ២០២៣ ទោះបីជាមានសម្ពាធពីខាងក្រៅក៏ដោយ កម្ពុជាអាចរក្សាបាននៅអត្រាប្តូរប្រាក់ខ្មែររៀលក្នុងកម្រិតមានស្ថិរភាពនេះគឺជាការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាផងដែរ។

ទោះបីជាមានការកើនឡើងនៃហានិភ័យឥណទានក៏ដោយ ក៏ប្រព័ន្ធធនាគារនៅតែមានភាពធន់ និងបន្តផ្តល់មូលនិធិដើម្បីគាំទ្រដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយជំងឺរាតត្បាត។ គុណភាពឥណទានសម្រាប់វិស័យទាំងមូលមានភាពយ៉ាប់យ៉ឺន ប៉ុន្តែនៅតែអាចគ្រប់គ្រងបានជាមួយនឹងការរៀបចំសំវិធានធនគ្រប់គ្រាន់ និងទ្រនាប់ដើមទុនរឹងមាំផងដែរ។ ចំណែកសម្រាប់អាយភីអា កម្ចីមិនដំណើរការ(NPL) នៅចុងឆ្នាំ ២០២៣ បានកើនឡើងដល់ ៤.១៧% ទោះជាយ៉ាងណាក៏ដោយ អាយភីអា ក៏បានបង្កើតទុនបម្រុងសម្រាប់ការបាត់បង់ប្រាក់កម្ចីនោះនៅចំនួន ៣.៤% ដើម្បីគ្របដណ្តប់ហានិភ័យឥណទានយឺតទាំងនោះ។ IPR បានផ្តល់ការរៀបចំឥណទានឡើងវិញសម្រាប់អតិថិជនដែលកំពុងប្រឈមមុខនឹងបញ្ហាសាច់ប្រាក់ក្នុងរយៈពេលខ្លីដោយសារការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ដែលមានអត្រា ២.៩% នៃផលបត្រឥណទានសរុប ដើម្បីធានាថាអតិថិជនរបស់ អាយភីអា អាចទប់ទល់នឹងការធ្លាក់ចុះសេដ្ឋកិច្ចរបស់ពួកគេ។

បើប្រៀបធៀបទៅនឹងឆ្នាំមុន ផលប័ត្រឥណទានរបស់ អាយភីអា មានការថយចុះ ដោយសារការកាត់បន្ថយនៅប្រាក់កម្ចីដល់បុគ្គលពាក់ព័ន្ធ និងការពង្រឹងដំណើរការវាយតម្លៃប្រាក់កម្ចីអោយបានតឹងរឹង។ ទោះយ៉ាងណាក៏ដោយ អាយភីអាអាចរក្សាការអនុវត្តរបស់ខ្លួនឱ្យស្ថិតក្រោមកម្រិតគ្រប់គ្រងបានសម្រាប់ឆ្នាំ២០២៣ ដោយប្រាក់ចំណេញសុទ្ធធៀបនឹងទ្រព្យសកម្ម (ROA) និងប្រាក់ចំណេញសុទ្ធធៀបនឹងមូលធន (ROE) មានចំនួន ៣.១% ទាំងពីរ ដែលធ្លាក់ចុះពី ៤.៤% និង ៤.៥% ក្នុងឆ្នាំ២០២២ រៀងគ្នា។ ទោះជាយ៉ាងណាក្តី អាយភីអា ប្រកាន់ខ្ជាប់នូវអាទិភាពកំពូលរបស់យើង ដែលធានាថាយើងនឹងផ្តល់ជំនួយដល់អតិថិជន និងនិយោជិតរបស់យើង គ្រប់កាលៈទេសៈដែលចាំបាច់។ ខ្ញុំសូមអរគុណចំពោះការណែនាំរបស់ក្រុមប្រឹក្សាភិបាល និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងគណៈគ្រប់គ្រងរបស់អាយភីអាផងដែរ។

អាយភីអា មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការបន្តអនុវត្តតាមក្រមប្រតិបត្តិរបស់ស្ថាប័នធនាគារ និងហិរញ្ញវត្ថុដែលបានដាក់ចេញក្នុងឆ្នាំ២០២២ ហើយក្រមប្រតិបត្តិនេះមានសារៈសំខាន់ក្នុងការផ្តល់ប្រាក់កម្ចីដោយការទទួលខុសត្រូវជូនដល់អតិថិជន ហើយអតិថិជនទទួលបានសេវាកម្មដែលមានភាពយុត្តិធម៌ និងក្រមសីលធម៌វិជ្ជាជីវៈ។ ជាការពិតណាស់ អាយភីអា មានតួនាទីក្នុងការចូលរួមបន្តពង្រឹងទំនុកចិត្តលើប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុទាំងមូលនៃប្រទេសកម្ពុជា។ បច្ចុប្បន្នអាយភីអាកំពុងដំណើរការក្នុងការបំពេញជំហានដែលតម្រូវដើម្បីអនុលោមតាមគោលការណ៍គាំពារអតិថិជន។

នៅឆ្នាំខាងមុខនេះ អាយភីអា មានគម្រោងកែប្រែយុទ្ធសាស្ត្ររបស់ខ្លួន និងសម្រួលដំណើរការប្រតិបត្តិការរបស់ខ្លួន ដើម្បីបន្តការវិវត្តន៍ជាមួយនឹងទីផ្សារ និងការអភិវឌ្ឍន៍បច្ចេកវិទ្យា ដើម្បីបម្រើអតិថិជនរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនឹងនេះ អាយភីអា សន្យាថានឹងពង្រឹងប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់ខ្លួនផងដែរ។ សមត្ថភាពរបស់បុគ្គលិក IPR បន្តដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រដល់ភាពរឹងមាំរបស់ក្រុមហ៊ុន ហើយ អាយភីអា ប្តេជ្ញាបន្តធានាថា ការគាំទ្រចាំបាច់ត្រូវបានផ្តល់ជូនដល់និយោជិត ដើម្បីឱ្យពួកគេអនុវត្តការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ក្នុងឆ្នាំ២០២៣ អាយភីអា បានចុះឈ្មោះបុគ្គលិកឥណទានទាំងអស់ដើម្បីឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវដែលនេះជាការតម្រូវចាំបាច់ដោយ ធនាគារជាតិនៃកម្ពុជា ដើម្បីធានាថាមន្ត្រីឥណទានទាំងអស់មានវិជ្ជាជីវៈច្បាស់លាស់ក្នុងការផ្តល់សេវាប្រាក់កម្ចីដោយភាពទទួលខុសត្រូវ។ អាយភីអា នឹងបន្តពង្រឹងសមត្ថភាព និងការអភិវឌ្ឍន៍បុគ្គលិករបស់ខ្លួនតាមរយៈការបណ្តុះបណ្តាលទាំងខាងក្នុង និងខាងក្រៅ។ លើសពីនេះ ស្របតាមចក្ខុវិស័យ និងបេសកកម្មរបស់ អាយភីអា យើងបាននឹងកំពុងធ្វើការលើដំណើរការគម្រោងខ្សែសង្វាក់កសិកម្មជាមួយដៃគូសំខាន់គឺក្រុមហ៊ុនបៃតង(កម្ពុជា) ហើយអាយភីអា គ្រោងនឹងចាប់ផ្តើមអនុវត្តគម្រោងនេះដោយមានគោលការណែនាំច្បាស់លាស់មួយនៅក្នុងឆ្នាំខាងមុខនេះ។

ជំនួសអោយគណៈគ្រប់គ្រងរបស់ អាយភីអា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះអស់ពីចិត្តចំពោះបុគ្គលិក គ្រប់ជាន់ថ្នាក់ ក្រុមប្រឹក្សាភិបាល ម្ចាស់ភាគហ៊ុន និងវិនិយោគិនសម្រាប់ការគាំទ្រ និងការណែនាំទាំងឡាយនាពេលកន្លងមក។ សូមអរគុណដល់ ដៃគូពាក់ព័ន្ធ និង CMA នៅការគាំទ្រ និងជំនួយកន្លងមក រួមទាំងធនាគារជាតិនៃកម្ពុជា សម្រាប់ការគាំទ្រជាបន្តបន្ទាប់ និងការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន។ យើងខ្ញុំនឹងបន្តកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការរួមជាមួយនឹងការឆ្លុះបញ្ចាំងជាបន្តបន្ទាប់ ដើម្បីកែលម្អ និងអភិវឌ្ឍន៍អាយភីអា និងអ្នកពាក់ព័ន្ធរបស់យើងខ្ញុំ។

**ភួ សុវណ្ណច័ន្ទ**
**នាយិកាប្រតិបត្តិ**

# ក្រុមប្រឹក្សាភិបាល



## លោកឧកញ៉ា ភួ ពុយ
### ប្រធានក្រុមប្រឹក្សាភិបាល

**លោកឧកញ៉ា ភួ ពុយ** ជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឥណទានពលរដ្ឋរុងរឿង អិលធីឌី ចាប់តាំងពីការចាប់ផ្តើមដំបូងនៃការកកើតគ្រឹះស្ថាន។ លោកឧកញ៉ាជាសហគ្រិនកសិកម្មឈានមុខគេម្នាក់ ជាពិសេសនៅក្នុងវិស័យម៉ាស៊ីនកិនស្រូវ។ លោកក៏ជាប្រធាន និងជានាយកប្រតិបត្តិនៃក្រុមហ៊ុនបៃតង (កម្ពុជា) ភីអិលស៊ី ដែលជាក្រុមហ៊ុនម៉ាស៊ីនកិនស្រូវធំជាងគេបង្អស់នៅកម្ពុជា។



## លោក ហ្សុំ មីងយី
### អភិបាលឯករាជ្យ

**លោក ហ្សុំ មីងយី** បច្ចុប្បន្នជាទីប្រឹក្សាឯករាជ្យក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងជាវិនិយោគិនមួយរូបផងដែរ។ លោកធ្លាប់បំរើការងារក្នុងគ្រឹះស្ថានឥណទានពលរដ្ឋរុងរឿង ជាទីប្រឹក្សានិងជានាយកប្រតិបត្តិការ។ លោកក៏ធ្លាប់បម្រើការងារនៅ ADA ដែលនៅទីនោះ លោកបានចូលរួមក្នុងការសម្របសម្រួលបង្កើតមូលនិធិអភិវឌ្ឍន៍មីក្រូហិរញ្ញវត្ថុលុចហ្សំបួរ និងជាអ្នកគ្រប់គ្រងផលប័ត្រវិនិយោគនៅក្នុងតំបន់អាស៊ី និងអាហ្វ្រិកខាងកើត។ លោកក៏មានបទពិសោធន៍ធ្វើការជាមួយគណកម្មការអឺរ៉ុប ជាមន្ត្រីសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅក្នុងប្រទេសម៉ាឡេស៊ី រួមទាំងធនាគារកណ្តាលរបស់ប្រទេសលុចហ្សំបួរ។ បន្ថែមពីលើនេះទៀត លោកមានស្នាដៃបោះពុម្ពផ្សាយការងារពាក់ព័ន្ធនឹងស្ថិរភាពហិរញ្ញវត្ថុ វិស័យមីក្រូហិរញ្ញវត្ថុ និងអត្រាសន្សំប្រាក់ផ្ទាល់ខ្លួនរបស់អាមេរិកផងដែរ។



## លោកស្រី ប៉ុក នីរីល័យ
### អភិបាលឯករាជ្យ

**លោកស្រី ប៉ុក នីរីល័យ** ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យតាំងពីខែមេសា ឆ្នាំ ២០១៦។ លោកស្រីមានបទពិសោធន៍ការងារជាច្រើនឆ្នាំលើផ្នែកលក់ ផ្នែក ទីផ្សារ និងផ្នែកទំនាក់ទំនងសាធារណៈ។ លោកស្រីធ្លាប់បានបំពេញ ការងារជានាយកទីផ្សារ និងទំនាក់ទំនងសាធារណៈ ជាប្រធានគ្រប់គ្រងផ្នែកលក់ និងជាអ្នកសម្របសម្រួល នៅក្នុងកម្មវិធីទូរទស្សន៍លើការជជែកពិភាក្សាពីផ្នែកច្បាប់ និងសុខភាព។ លោកស្រី នីរីល័យ ទទួលបានបរិញ្ញាប័ត្រ និងបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម លើជំនាញគ្រប់គ្រងទូទៅ។



## លោក ប៉ិច សានី
### អភិបាលឯករាជ្យ

**លោក ប៉ិច សានី** បានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ក្នុងខែមករាឆ្នាំ២០២០។ លោកមានតំណែងជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានប្រតិបត្តិការ និងកិច្ចការរតនាគារ និងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)។ លោក ប៉ិច សានី មានបទពិសោធន៍ការងារក្នុងវិស័យធនាគារជាង២០ឆ្នាំមកហើយ។ មុននឹងចូលបម្រើការងារនៅធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ក្នុងឆ្នាំ២០០១ លោកបានបម្រើការងារ និងមានបទពិសោធន៍ការងារជាច្រើននៅធនាគារជាតិនៃកម្ពុជា និងនៅធនាគារពាណិជ្ជ។ លោក បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកធនាគារ ពីសកលវិទ្យាល័យធនាគារ ក្នុងប្រទេសវៀតណាម និងបានបញ្ចប់ថ្នាក់ អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ពីសកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៤។

# គណៈគ្រប់គ្រង

## ក្រុមហ៊ុន



### កញ្ញា ភួ សុវណ្ណច័ន្ទ

**នាយិកាប្រតិបត្តិ**

**កញ្ញា ភួ សុវណ្ណច័ន្ទ** ត្រូវបានតែងតាំងជានាយិកាប្រតិបត្តិនៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០២១។ គាត់ធ្លាប់បានបំពេញតួនាទីជា មន្រ្តីប្រតិបត្តិតាម នៅក្នុងគ្រឹះស្ថាន ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៩។ ពីមុនមក គាត់បានបំពេញការងារជាជំនួយការនាយកប្រតិបត្តិ ហាត់ការរយៈពេល ៦ ខែក្នុងឆ្នាំ២០១៨។

សុវណ្ណច័ន្ទ បានទទួលសញ្ញាបត្របរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច ជំនាញគណនេយ្យ និងហិរញ្ញវត្ថុពី CamEd Business School, ហើយក្នុងអំឡុងពេលជាមួយគ្នានោះ កញ្ញាទទួលបានសញ្ញាបត្រ Certified Accounting Technician (CAT) ផងដែរ។ ក្រោយមក នៅឆ្នាំ២០២០ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ ពីសកលវិទ្យាល័យ Grenoble École de Management នៅប្រទេសសឹង្ហបុរី និង អំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឆ្នាំទី២ គាត់បានចាប់ផ្តើមការងារជាមួយគ្រឹះស្ថានជា មន្រ្តីប្រតិបត្តិតាម ដែលជាពេលដែលគាត់បានទទួលវិញ្ញាបនបត្រ Regulatory Compliance Certificate ពីវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលជាកម្មសិទ្ធិរបស់សមាគមធនាគារកម្ពុជា។ បច្ចុប្បន្ន សុវណ្ណច័ន្ទកំពុងបន្តការសិក្សាជំនាញ Charter Banker ដែលផ្តល់ជូនដោយ Charter Banker Institute, ពីចក្រភពអង់គ្លេស។



### លោក ចេង វណ្ណេត

**នាយកប្រតិបត្តិការ**

**លោក ចេង វណ្ណេត** បំពេញតួនាទីជានាយកប្រតិបត្តិការតាំងពីខែកញ្ញា ឆ្នាំ២០១៩។ លោកចាប់ផ្តើមការងារដំបូង នៅក្នុងគ្រឹះស្ថាន ក្នុងខែមករា ឆ្នាំ២០១០ និងបានបម្រើការងារក្នុងមុខតំណែងជាច្រើន ដូចជា ប្រធានផ្នែកស្តារបំណុល ប្រធានសាខាមេ ប្រធានផ្នែកឥណទាន នាយកប្រតិបត្តិការស្តីទី និងនាយកសវនកម្មផ្ទៃក្នុងផងដែរ។ មុនបម្រើការងារនៅទីនេះ លោកធ្លាប់បម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងក្នុងតួនាទីជាមន្រ្តីឥណទាន និងប្រធានផ្នែកប្រតិបត្តិការ។

លោក វណ្ណេត បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ច និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាញគ្រប់គ្រងពីសកលវិទ្យាល័យបញ្ញាជាតិ ក្នុងឆ្នាំ២០១៤ និង បរិញ្ញាបត្រវិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាញអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទពីសកលវិទ្យាល័យភូមិន្ទនិតិសាស្រ្តនិងសេដ្ឋកិច្ច។ ក្រៅពីនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងការគ្រប់គ្រងក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។

# គណៈគ្រប់គ្រង
# ក្រុមហ៊ុន



## លោក ហៃ គីមឃន
### នាយកហិរញ្ញវត្ថុ និងរដ្ឋបាល

**លោក ហៃ គីមឃន** ជានាយកហិរញ្ញវត្ថុតាំងពីឆ្នាំ ២០០៩ ។ លោកបានបំពេញការងារជាមួយគ្រឹះស្ថានមានរយៈពេលច្រើន ជាង ១៧ឆ្នាំ ចាប់តាំងពីឆ្នាំ២០០៦ ក្នុងមុខតំណែងផ្សេងៗគ្នាជាច្រើនដូចជា ជំនួយការប្រធានសាខា ប្រធានសាខា និងនាយកប្រតិបត្តិការ។ មុនចូលបំពេញការងារនៅទីនេះ លោកជាអ្នកកាន់បញ្ជីគណនេយ្យក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ។

លោក គីមឃន បានទទួលបរិញ្ញាប័ត្រផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង។ ក្រៅពីនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងការគ្រប់គ្រងក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។



## លោក គៀក កោវិទ្ធ
### នាយកព័ត៌មានវិទ្យាស្តីទី

**លោក គៀក កោវិទ្ធ** បានតែងតាំងជាប្រធានបច្ចេកវិទ្យាព័ត៌មាន ក្នុងខែកុម្ភៈ ឆ្នាំ២០២០។ លោកធ្លាប់ជាប្រធានបច្ចេកវិទ្យាព័ត៌មាន នៅក្រុមហ៊ុនលីហ្សូរប្តូរប្រាក់ក្នុងឆ្នាំ២០១៨ រួមទាំងជាអ្នកគ្រប់គ្រង ជាន់ខ្ពស់នៅក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតព្រូដិនសលកម្ពុជាក្នុងឆ្នាំ២០១៧។ នៅក្នុងឆ្នាំ២០១៥ លោកមានតួនាទីជាអ្នកសរសេរកម្មវិធីជាន់ខ្ពស់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។ ក្រៅពីនេះ លោកធ្លាប់បានដឹកនាំគម្រោងជាច្រើនក្នុងការចូលរួមកម្មវិធី I-ENVEX-2014 នៅប្រទេសម៉ាឡេស៊ី។

លោកកោវិទ្ធ បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកវិទ្យាសាស្រ្តកុំព្យូទ័រ ពីសកលវិទ្យាល័យន័រតុន និងមានជំនាញក្នុងការបង្កើត និងគ្រប់គ្រងប្រព័ន្ធស្នូល របាយការណ៍MIS ឃ្លាំងទិន្នន័យ In-House Application និងជំនួយផ្សេងៗ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមទាំងក្រុមហ៊ុនធានារ៉ាប់រងផងដែរ។



## លោក សេង កក្កដា
### នាយកសវនកម្មផ្ទៃក្នុងស្តីទី

**លោក សេង កក្កដា** ត្រូវបានតែងតាំងជាប្រធានសវនកម្មផ្ទៃក្នុងនៅ ឥណទានពលរដ្ឋរុងរឿង អិលធីឌី ក្នុងខែឧសភា ឆ្នាំ ២០២០។ ពីមុនលោកធ្លាប់មានបទពិសោធន៍ការងារជាង ៦ ឆ្នាំនៅក្នុងវិស័យហិរញ្ញវត្ថុក្នុងតួនាទីជាច្រើនដូចជា មន្ត្រីឥណទានជាន់ខ្ពស់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាមិក ភីអិលស៊ី ជាសវនករផ្ទៃក្នុងនៅគ្រឹះស្ថាន ឥណទានពលរដ្ឋរុងរឿង និង ជាអ្នកវិភាគឥណទាន នៅធនាគារ កាណាឌីយ៉ា។

លោក កក្កដា មានសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យន័រតុន និងបរិញ្ញាបត្រផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញហិរញ្ញវត្ថុ និងធនាគារ ពីសកលវិទ្យាល័យធនធានមនុស្ស។

# ភាគទុនិក និងវិនិយោគិន



## វិនិយោគិន

**លោកឧកញ៉ា ភួ ពុយ**
ភាគទុនិកតែម្នាក់គត់ និងជាស្ថាបនិកនៃគ្រឹះស្ថាន
មីក្រូហិរញ្ញវត្ថុ ឥណទានពលរដ្ឋរុងរឿង អិលធីឌី។



# អង្គការលេខ


ក្រុមប្រឹក្សាភិបាល
គណៈកម្មការសវនកម្ម និងហានិភ័យ
នាយកប្រតិបត្តិ
នាយកដ្ឋានប្រតិបត្តិការ
នាយកដ្ឋានហិរញ្ញវត្ថុ និងរដ្ឋបាល
នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានវិទ្យា
ផ្នែកប្រតិបត្តិតាម និងហានិភ័យ
នាយកដ្ឋានសវនកម្មផ្ទៃក្នុង
ស្នាក់ការសាខា ០០២
ស្នាក់ការសាខា ០០៣
ស្នាក់ការសាខា ០០៤
ស្នាក់ការសាខា ០០៥
ស្នាក់ការសាខា ០០៦
ស្នាក់ការសាខា ០០៧
ស្នាក់ការសាខា ០០១០


គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

# រចនាសម្ព័ន្ធសាខា


ប្រធានសាខា
អនុប្រធានសាខា
មន្ត្រីឥណទាន
មន្ត្រីឥណទាន
មន្ត្រីឥណទាន
មន្ត្រីឥណទាន
មន្ត្រីឥណទាន
គណនេយ្យករសាខា
ហេរញ្ញិកសាខា
សន្តិសុខ



# អតិថិជនគោលដៅ
# និងផលិតផល

## ផលិតផល អាយភីអេ

អាយភីអេ បានបន្តកែប្រែគោលនយោបាយ និងនីតិវិធីឥណទានរបស់ខ្លួន ហើយបានបង្កើតគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ក្នុងការសម្របខ្លួនទៅនឹងគោលគំនិតនៃស្តង់ដារនៃការគាំពារអតិថិជន សម្រាប់ប្រតិបត្តិការ និងការអនុវត្តប្រចាំថ្ងៃនៅគ្រប់សាខារបស់អាយភីអេ។ ផលិតផលកម្ចីមានស្រាប់ត្រូវបានកែប្រែ ហើយផលិតផលកម្ចីថ្មីត្រូវបានបង្កើតឡើងដើម្បីបំពេញតំរូវការរបស់អតិថិជនជាពិសេសប្រជាជនដែលមានចំណូលទាប និងមធ្យមទនៅតំបន់ជនបទនៃប្រទេសកម្ពុជា។ ការធ្វើពិពិធកម្មផលិតផលកម្ចីផ្សេងៗ គ្មានគោលបំណងដើម្បីទទួលបានអតិថិជនកាន់តែច្រើន។ បញ្ជីរាយនាមផលិតផលកម្ចី និងអតិថិជនគោលដៅមានដូចខាងក្រោម៖

### ឥណទាន កសិកម្ម



ផ្តោតសំខាន់ចំពោះកសិករទូទៅ និងសមាជិកសហគមន៍បៃតង ដែលត្រូវការឥណទានដើម្បីទិញគ្រាប់ពូជ ជី ថ្នាំ ប្រេង និងសម្ភារៈដាំដុះផ្សេងៗទៀត។

### ឥណទានបង្កើនទ្រព្យ



អតិថិជនឯកត្តបុគ្គលដែលត្រូវការឥណទានដើម្បីទិញដីបន្ថែមសម្រាប់ធ្វើកសិកម្ម និងដើម្បីកែលំអរគេហដ្ឋានឲ្យប្រសើរជាងមុន

### ឥណទានទូដែក



អាជីវករខ្នាតតូចនិងមធ្យម និងសហគ្រាសផលិតដែលត្រូវការឥណទាន ដើម្បីទ្រទ្រង់អាជីវកម្ម និងប្រតិបត្តិការ

### ឥណទាសំភារៈកសិកម្ម



អតិថិជនឯកត្តបុគ្គលដែលត្រូវការឥណទានដើម្បីទិញឧបករណ៍ ម៉ាស៊ីន គ្រឿងចក្រ និងតម្រូវការផ្សេងៗទៀតទាក់ទងនឹងផលិតកម្មកសិកម្ម។

### ឥណទានអាជីវកម្ម



អាជីវករខ្នាតតូច និងមធ្យម និងសហគ្រាសផលិតដែលត្រូវការឥណទាន ដើម្បីទ្រទ្រង់អាជីវកម្ម និងប្រតិបត្តិការ

### ឥណទានម៉ូតូ



អតិថិជនឯកត្តបុគ្គល រស់នៅទីក្រុងឬជនបទដែលត្រូវការឥណទានដើម្បីទិញម៉ូតូ

### ឥណទានសម្ភារប្រើប្រាស់ក្នុងគេហដ្ឋាន



អតិថិជនជាម្ចាស់ផ្ទះ ដែលត្រូវការឥណទានដើម្បីទិញសម្ភារប្រើប្រាស់ក្នុងគេហដ្ឋាន មានដូចជា ទូទឹកកក ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនត្រជាក់ ទូរទស្សន៍ គ្រឿងសង្ហារឹម ទូរស័ព្ទ ល។

### ឥណទានប្រ៊ីដជីង ( Bridging )



អតិថិជនឯកត្តបុគ្គល អាជីវករ និងសហគ្រាស ដែលត្រូវការឥណទានសម្រាប់រយៈពេលខ្លី ដោយសារខ្វះទុនក្នុងរយៈពេលខ្លី ឬកំពុងរងចាំការសងប្រាក់ត្រលប់ពីអតិថិជនរបស់គាត់

# អតិថិជនគោលដៅ

## កសិករ

កសិករ ដែល ត្រូវការប្រាក់សម្រាប់ជួយដល់សកម្មភាពធ្វើកសិកម្មវិនិយោគលើ ឧបករណ៍ធុនធ្ងន់ ឬ ទិញដីកសិកម្មបន្ថែម។






## ម្ចាស់អាជីវកម្ម ខ្នាតតូច

ម្ចាស់អាជីវកម្មខ្នាតតូច ហាងលក់រាយ ហាងលក់គ្រឿងទេស ហាងលក់សំលៀកបំពាក់ អ្នកផ្តល់សេវាកម្មជាដើម ដែលត្រូវការដើមទុនធ្វើការដើម្បីផ្គត់ផ្គង់តម្រូវការអាជីវកម្ម និងប្រតិបត្តិការរបស់ពួកគេ។






## សហគ្រាសធុនតូច និងមធ្យម

សហគ្រាសធុនតូច និងមធ្យម ដែលបានចុះបញ្ជី ក្រុមហ៊ុនឯកជន ក្រុមហ៊ុនលក់រាយ ដេប៉ូ ផ្សារទំនើប ជាដើម ដែលប្រឈមមុខនឹងបញ្ហាសាច់ប្រាក់ក្នុងកំឡុងពេលជាក់លាក់ណាមួយ ដើម្បីផ្គត់ផ្គង់តម្រូវការជាក់លាក់របស់ពួកគេ ដើម្បីបំពេញភាគហ៊ុន ឬសងប្រាក់កម្ចីរបស់ពួកគេជាមួយធនាគារ ឬស្ថាប័នហិរញ្ញវត្ថុ។






## អតិថិជនផ្សេងទៀត

អតិថិជនទូទៅផ្សេងទៀត រួមមានសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុនឯកជន (ដែលមានប្រាក់បៀវត្សរ៍ប្រចាំខែទៀងទាត់) ដែលចង់ទិញម៉ូតូ ឬ គ្រឿងប្រើប្រាស់ក្នុងផ្ទះ (ទូទឹកកក ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបោកគក់ ទូរទស្សន៍ ម៉ាស៊ីនបូមទឹក ចង្កៀងសូឡា។ល។ ...) សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីផ្តល់លក្ខខណ្ឌរស់នៅកាន់តែប្រសើរ ឬការកម្សាន្តសម្រាប់គ្រួសាររបស់ពួកគេ។

# លទ្ធផលការងារ
## ឆ្នាំ២០២៣



# ទិន្នន័យសំខាន់ៗ

| សូចនាករ | ខ្នាត | សវនកម្មឆ្នាំ ២០២៣ | សវនកម្មឆ្នាំ ២០២២ | សវនកម្មឆ្នាំ ២០២១ | សវនកម្មឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ចំនួនខេត្តប្រតិបត្តិការ | - | ៥ | ៥ | ៥ | ៨ |
| ចំនួនស្រុកប្រតិបត្តិការ | - | ៣២ | ៣៦ | ៣២ | ៣៨ |
| ចំនួនឃុំប្រតិបត្តិការ | - | ១២៧ | ១៣៦ | ១៣៨ | ១៦៤ |
| ចំនួនភូមិប្រតិបត្តិការ | - | ៤៩២ | ៥១២ | ៤៩៤ | ៥២៦ |
| ចំនួនបុគ្គលិក | - | ៧៣ | ៧២ | ៧២ | ៧៦ |
| ចំនួនអតិថិជនសរុប | - | ២,០៣៥ | ២,១១៩ | ១,៩៤៩ | ១,៩៨៧ |
| ផលប័ត្រឥណទានសរុប | US$ | ៦,៥៨៧,៣៣៦ | ៧,០៦០,៥៥៩ | ៦,៨០៨,០៨៤ | ៦,៤៥៧,៦១១ |
| ចំណេញសុទ្ធ | US$ | ២៣២,៨១៥ | ៣៣៨,៨១០ | ១៧៩,៣៤៣ | ៥០៩,៤៧៤ |
| ទ្រព្យសកម្មសុទ្ធ | US$ | ៧,៦៧៣,៦០៤ | ៧,៤៧៣,៦៥១ | ៨,០២៨,៥៧០ | ៧,៨៦២,០៤៤ |
| មូលធនសរុប | US$ | ៧,៦១១,២៩៤ | ៧,៣៧៨,៤៧៩ | ៧,៣៧៨,៤៧៩ | ៧,៣៧៨,៤៧៩ |
| អតិថិជនកម្ចីជាស្ត្រី | % | ៦០,៩៨ | ៦៧,០១ | ៧៧,៩៤ | ៨៦,៧១ |
| អតិថិជនកម្ចីនៅជនបទ | % | ៩៧,៦២ | ៩៧,៦២ | ៩៥,៤៣ | ៩៥,២២ |
| កម្ចីកសិកម្ម | % | ៤០ | ៣៤,០១ | ៤២,៦៨ | ៤៨,៩០ |
| ហានិភ័យឥណទាន | % | ៤,១៧ | ៣,១៣ | ២,០៥ | ២,២៩ |
| ឥណទានលុបចេញពីបញ្ជី | % | ២,៨៧ | ០,៦៩ | ១,៤៦ | ១,៩៦ |
| ទិន្នផលផលប័ត្រឥណទាន | % | ១៨,៧៣ | ១៩,៦៣ | ១៨,៦៨ | ២១,៨១ |
| ចំណាយលើមូលនិធិ | % | ០,០០ | ០,២៥ | ០,៤៣ | ០,៤៧ |
| ចំណាយប្រតិបត្តិការ | % | ១២,៥៧ | ១២,០៨ | ១៤,១ | ១៣,៩ |
| ប្រាក់ចំណេញសុទ្ធធៀបនឹងទ្រព្យសកម្ម | % | ៣,១ | ៤,៤ | ១,៩២ | ៦,៧ |
| ប្រាក់ចំណេញសុទ្ធធៀបនឹងមូលធន | % | ៣,១ | ៤,៥ | ២,០២ | ៧,០៤ |
| បំណុលធៀបនឹងមូលធន | % | ១ | ៥ | ៥ | ៥ |
| ភាពគ្រប់គ្រាន់ផ្ទាល់លើប្រតិបត្តិការ | % | **១៣១** | **១៥៦** | **១៣០** | **១៨៦** |

# លទ្ធផលការងារ

## ផលបត្រឥណទាន






# ផលបត្រឥណទាន (បន្ត)






# អនុបាតហិរញ្ញវត្ថុ






## អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម ( ROA ) និងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុន ( ROE )




## ចំនួនផលបត្រឥណទាន និង ចំនួនអតិថិជនដែលបានបញ្ចេញ



# បទពិសោធន៍
# របស់អតិថិជន





**អ្នកស្រី លាង ថាវ័ន្ត នៅភូមិកំពង់ចម្លងលើ ឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង**

អ្នកស្រី លាង ថាវ័ន្ត ជាកសិករធ្វើចំការ ដាំដំណាំពោត និងដំឡូងមីនៅចំការរបស់គាត់ និងមានមុខរបរបន្ទាប់បន្សំផ្សេងទៀតដូចជា ដាំល្ពៅ សណ្តែកគួរ ពោតស ខ្ទឹម ម្ទេស ត្រប់ ទំពាំង ជាដើម។ គាត់ជាអតិថិជនជោគជ័យម្នាក់របស់អាយភីអានៅសាខាភ្នំព្រឹក។ អ្នកស្រីជាអតិថិជនដ៏ស្មោះត្រង់ម្នាក់របស់យើង តាំងពីឆ្នាំ២០១១ មកម្លេះ ហើយគាត់បានបន្តប្រើប្រាស់ប្រាក់កម្ចីចំនួន ៦វគ្គ មកហើយ គិតត្រឹមចុងឆ្នាំ២០២៣។ វគ្គទី១ ឆ្នាំ២០១១ បានខ្ចីចំនួន៨.០០០ដុល្លារ យកទិញត្រាក់ទ័រ ហើយនៅតែបន្តកម្ចីជាបន្តបន្ទាប់ក្នុងគោលបំណងពង្រីកអាជីវកម្មកសិកម្មបន្ថែម និងចុងក្រោយឆ្នាំ២០២៣ វគ្គទី៦ នេះគាត់ខ្ចី ២.៥០០ដុល្លារ យកទៅពង្រីកអាជីវកម្មកសិកម្មបន្ថែមដូចគ្នា។ ទំហំកម្ចីជាមធ្យមរបស់អ្នកស្រី លាង ថាវ័ន្ត មានចន្លោះពី ២.៥០០ដុល្លារ ដល់ ៨.០០០ ដុល្លារអាមេរិក។ តាមរយៈប្រាក់កម្ចីរបស់អ្នកស្រីជាមួយអាយភីអាបានធ្វើឱ្យគាត់មានលទ្ធភាពចំណាយក្នុងការថែទាំសុខភាពគ្រួសារ មានអាហារល្អ និងអាចចំណាយក្នុងការធ្វើដំណើរកម្សាន្តជាលក្ខណៈគ្រួសារផងដែរ។ បន្ថែមពីនេះ ធ្វើឱ្យទ្រព្យសម្បត្តិរបស់គាត់បានកើនឡើងជាលំដាប់ដូចជា ពីមុនទទួលកម្ចីពីអាយភីអា មានដីចំការត្រឹមតែ ៣ហិតា គ្មានឧបករណ៍គ្រឿងយន្ត ឬ ម៉ាស៊ីនបូមទឹកសម្រាប់ប្រើប្រាស់។ ប៉ុន្តែបច្ចុប្បន្នអ្នកស្រី លាង ថាវ័ន្ត មានដីចំការរហូតដល់៦ហិចតា មានត្រាក់ទ័រ១គ្រឿង ម៉ាស៊ីនបូមទឹក១គ្រឿង ម៉ូតូ៣គ្រឿង និងកែលម្អផ្ទះបានល្អប្រសើរជាងមុន សម្រាប់ជាជម្រកដ៏កក់ក្តៅដល់សមាជិកគ្រួសារ។ សំខាន់ជាងនេះទៅទៀត អ្នកស្រីអាចបន្តផ្គត់ផ្គង់ការសិក្សារបស់កូនៗ និងសម្ភារសិក្សារបស់ពួកគេតាមតម្រូវការ។

# បទពិសោធន៍ របស់អតិថិជន





## លោក សូត្រ វិន នៅភូមិតាស្ដា ឃុំតាស្ដា ស្រុកសំពៅលូន ខេត្តបាត់ដំបង

លោក សូត្រ វិន ជាកសិករធ្វើចំការ ដាំដំណាំចម្រុះវិលជុំដូចជា ពោត ដំឡូងមី និងដំណាំហូបផ្លែនៅចំការរបស់គាត់ និងមានមុខរបរបន្ទាប់បន្សំផ្សេងទៀតដូចជាដាំបន្លែ។ លោក សូត្រ វិន ជាអតិថិជនជោគជ័យម្នាក់របស់អាយភីអានៅសាខាសំពៅលូន។ គាត់ជាអតិថិជនដ៏ស្មោះត្រង់ម្នាក់របស់យើង តាំងពីឆ្នាំ២០១៩ មកម្លេះ ហើយគាត់បានបន្តប្រើប្រាស់ប្រាក់កម្ចីចំនួន ៨ វគ្គ មកហើយ គិតត្រឹមចុងឆ្នាំ២០២៣។ វគ្គទី១ ឆ្នាំ២០១៩ បានខ្ចីចំនួន៤០.០០០បាត យកទៅពង្រីកដាំណាំដំឡូមី និងពោត ហើយនៅតែបន្តកម្ចីជាបន្តបន្ទាប់ក្នុងគោលបំណងទិញដីចំការបន្ថែម និងពង្រីកការដាំដុះបន្ថែម និងចុងក្រោយឆ្នាំ២០២៣ វគ្គទី៨ នេះគាត់ខ្ចី ២០០.០០០បាត យកទៅរៀបចំប្រព័ន្ធស្រោចស្រពដំណាំ។ ទំហំកម្ចីជាមធ្យមរបស់លោក សូត្រ វិន មានចន្លោះពី ៤០.០០០បាត ដល់ ២០០.០០០បាត។ តាមរយៈប្រាក់កម្ចីរបស់លោកជាមួយ អាយភីអា បានធ្វើឱ្យគាត់មានលទ្ធភាពចំណាយក្នុងការថែទាំសុខភាពគ្រួសារ មានអាហារគ្រប់គ្រាន់ អាចទិញសំលៀកបំពាក់ជូនក្រុមគ្រួសារ និងសាងសង់បង្គន់អនាម័យជាដើម។ បន្ថែមពីនេះ ធ្វើឱ្យទ្រព្យសម្បត្តិរបស់គាត់បានកើនឡើងជាលំដាប់ដូចជា ពីមុនទទួលកម្ចីពីអាយភីអា មានដីចំការត្រឹមតែ ២០ហិចតា គ្មានឧបករណ៍គ្រឿងយន្ត ឬម៉ាស៊ីនបូមទឹកប្រើប្រាស់។ ប៉ុន្តែបច្ចុប្បន្នលោក សូត្រ វិន មានដីចំការរហូតដល់ ២៧ហិចតា មានត្រាក់ទ័រ ១គ្រឿង គោយន្ត១គ្រឿង ម៉ាស៊ីនភ្លើង១គ្រឿង ម៉ាស៊ីនបូមទឹក១គ្រឿង ម៉ូតូ៤គ្រឿង និងឡានដឹកទំនិញ១គ្រឿង។

# សវនកម្មផ្ទៃក្នុង
# និងការត្រួតពិនិត្យ

សវនកម្មផ្ទៃក្នុង ជានាយកដ្ឋានដែលមានវិជ្ជាជីវៈក្នុងការវាយតម្លៃ និងលើកកម្ពស់ប្រសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យ និងដំណើរការគ្រប់គ្រងអភិបាលកិច្ចក្នុងគ្រឹះស្ថាន។ សវនករផ្ទៃក្នុងធ្វើការជាមួយអ្នកគ្រប់គ្រងដើម្បីត្រួតពិនិត្យប្រព័ន្ធការងារ និងប្រតិបត្តិការរបស់គ្រឹះស្ថាន។ ការត្រួតពិនិត្យឡើងវិញទាំងនេះ សំដៅកំណត់ ថាតើហានិភ័យត្រូវបានគ្រប់គ្រងយ៉ាងដូចម្ដេច ដោយរាប់បញ្ចូល ថាតើដំណើរការដែលត្រឹមត្រូវមានហើយឬនៅ ហើយនីតិវិធីដែលបានព្រមព្រៀងគ្នាត្រូវបានអនុវត្តឬអត់។ ការធ្វើសវនកម្មផ្ទៃក្នុង ក៏អាចកំណត់អត្តសញ្ញាណតំបន់ដែលត្រូវបង្កើនប្រសិទ្ធិភាព ឬត្រូវដាក់ឲ្យប្រើប្រាស់នវានុវត្តន៍ថ្មី។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងមានបុគ្គលិកចំនួន ៣ នាក់ រួមមាននាយកសវនកម្មផ្ទៃក្នុង ១ នាក់ និងសវនករប្រតិបត្តិការចំនួន ២ នាក់។

ក្នុងឆ្នាំ២០២៣ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចុះធ្វើសនវកម្មចំនួន ៣ ជុំតាមសាខានីមួយៗ ដោយបានប្រើប្រាស់វិសាលភាពសវនកម្មពេញ។ ជាលទ្ធផលបង្ហាញថា ពិន្ទុនិងចំណាត់ថ្នាក់ហានិភ័យតាមសាខានីមួយៗ គឺហានិភ័យអាចទទួលយកបាន និងហានិភ័យកំរិតស្រាល។

ក្នុងឆ្នាំដដែល នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានរៀបចំកិច្ចប្រជុំចំនួន ៣ លើក សម្រាប់ការប្រជុំរបស់គណៈកម្មការសវនកម្ម ដើម្បីពិភាក្សាពីរបកគំហើញនានា និងគម្រោងដែនការសម្រាប់ឆ្នាំបន្ទាប់។

ក្នុងនាមជាលេខាធិការមួយរបស់គណកម្មការហានិភ័យ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានធ្វើជាទៀងទាត់នូវរបាយការណ៍ដែនកំណត់ហានិភ័យជាប្រចាំត្រីមាស និងការចុះបញ្ជីហានិភ័យជាប្រចាំខែ ទៅកាន់គណកម្មការហានិភ័យ និងក្រុមប្រឹក្សាភិបាល ដើម្បីត្រួតពិនិត្យ និងផ្ដល់អនុសាសន៍សម្រាប់ការកែលម្អ ក្នុងករណីដែលចាំបាច់។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានដាក់ឲ្យប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃ និងចំណាត់ថ្នាក់ហានិភ័យដែលឲ្យឈ្មោះថា ”Internal Audit Worksheet and Rating System” សម្រាប់ឥណទានមិនដំណើរការ និងឥណទានលុបចេញពីបញ្ជី។ ប្រព័ន្ធថ្មីនេះបានកំណត់នូវហានិភ័យជាក់លាក់ទៅលើ ការចំណាត់ការដោះស្រាយ និងតាមដានស្ថានភាពបំណុលតាមអតិថិជននីមួយៗ និងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលមិនល្អរបស់សាខា។








# បុគ្គលិក
# និងការកសាងសមត្ថភាព

| សូចនាករ | ២០២៣ | ២០២២ | ២០២១ | ២០២០ |
|---|---|---|---|---|
| **ព័ត៌មានបុគ្គលិក** | | | | |
| ចំនួនបុគ្គលិកសរុប | ៧៣ | ៧២ | ៧២ | ៧៦ |
| ចំនួនគណៈគ្រប់គ្រង | ១៤ | ១៤ | ១៣ | ១៤ |
| ភាគរយបុគ្គលិកការិយាល័យ | ៦២% | ៥៨% | ៥៨% | ៥៦% |
| ភាគរយបុគ្គលិកប្រតិបត្តិការ | ៣៨% | ៤២% | ៤៤% | ៤៤% |
| **កម្រិតការអប់រំរបស់បុគ្គលិក** | | | | |
| បរិញ្ញាបត្រជាន់ខ្ពស់ | ៥% | ៦% | ៦% | ៧% |
| បរិញ្ញាបត្រ | ៥៦% | ៥១% | ៤៩% | ៥០% |
| បរិញ្ញាបត្ររង និងទាបជាង | ៣៨% | ៤៣% | ៤៥% | ៤៣% |



# វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងឆ្នាំ ២០២៣





**វគ្គបណ្តុះបណ្តាលខាងក្នុង**

1. ការបណ្តុះបណ្តាលតម្រង់ទិសបុគ្គលិកថ្មីៗ
2. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីគោលការណ៍ និងនិតិវិធីឥណទាន
3. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីការគ្រប់គ្រងធនធានមនុស្ស និងរដ្ឋបាល
4. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីការគ្រប់គ្រងបណ្តឹងតវ៉ា និងព័ត៌មានត្រលប់
5. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីបទបញ្ជាផ្ទៃក្នុង
6. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីក្រមសីលធម៌
7. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីគោលការណ៍ព័ត៌មានវិទ្យា
8. ការបណ្តុះបណ្តាលស្តីពីគោលការណ៍ទទួលទ្រព្យបញ្ចាំ
9. ការបណ្តុះបណ្តាលរលឹកឡើងវិញអំពីជំនាញនៃការលក់
10. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីសេវាកម្មអតិថិជន
11. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីវិសាលភាពនៃសវនកម្មផ្ទៃក្នុង
12. ការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីគោលការណ៍នៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
13. ការបណ្តុះបណ្តាលស្តីពីវិន័យឥណទាន
14. ការបណ្តុះបណ្តាលស្តីពីប្រព័ន្ធស្វ័យមរកត

**វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាខាងក្រៅ**

1. ការគណនាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងពន្ធពន្យា
2. វិញ្ញាបនបត្រនៃការផ្តល់ប្រាក់កម្ចីដោយការទទួលខុសត្រូវ
3. តួនាទីនៃអ្នកគ្រប់គ្រងក្នុងការធានាការប្តេជ្ញាចិត្ត និងប្រសិទ្ធិភាពនៃការអនុវត្តតាមគោលការណ៍គាំពារអតិថិជនសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ
4. ប្រសិទ្ធិភាពនៃការគ្រប់គ្រងសាខា
5. សិក្ខាសាលាផ្សព្វផ្សាយស្តីពី ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការ រីកសាយភាយអាវុធមហាប្រល័យ នៅធនាគារជាតិនៃកម្ពុជា
6. សិក្ខាសាលាផ្សព្វផ្សាយស្តីពី របាយការណ៍ប្រចាំខែស្តីពី ឥណទានតាម វិស័យស្ថាប័ននិងសកម្មភាពសេដ្ឋកិច្ច
7. សិក្ខាសាលាស្តីអំពីកាលវិភាគនៃការផ្តល់ព័ត៌មានត្រលប់លើរបាយការណ៍ CTR and STR
8. សិក្ខាសាលាស្តីពីពី Gender, ផលិតផលហិរញ្ញវត្ថុទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ និងយន្តការដោះស្រាយបណ្តឹងតវ៉ារបស់អតិថិជន
9. សិក្ខាសាលាស្តីអំពីរបាយការណ៍ស្តីអំពីស្ថេរភាពហិរញ្ញវត្ថុ
10. ការប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ស្តង់ដាកិច្ចសន្យាឥណទាន និងខចែងស្តង់ដាកិច្ចសន្យាឥណទានសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
11. សិក្ខាសាលាស្តីអំពីការពង្រឹងបច្ចេកទេសសិក្សាវាយតម្លៃឥណទាន គ្រប់គ្រងផលបត្រ ជម្រុញការលក់ផលិតផលហិរញ្ញវត្ថុ និងការលក់ផលិតផលអនាម័យនិងទឹកស្អាត
12. សិក្ខាសិលាស្តីអំពី តួនាទីនៃអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការធានានូវការអនុវត្តកិច្ចការពារអតិថិជនប្រកបដោយ ប្រសិទ្ធភាព
13. សិក្ខាសាលាផ្សព្វផ្សាយអំពីការដាក់ដំណើការឧបករណ៍ត្រួតពិនិត្យផ្អែកលើ ហានិភ័យ ( Risk Based Supervision–RBS ) សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
14. សារាចរណែនាំស្តីពី ការរៀបចំឥណទានឡើងវិញចំពោះវិស័យទេសចរណ៍នៅ ខេត្តសៀមរាប
15. សិក្ខាសាលាផ្សព្វផ្សាយ តួនាទីរបស់ ស.ហ.ក និងបុគ្គលរាយការណ៍ចំពោះការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសម្រាប់ធនាគារ ឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

# ទំនួលខុសត្រូវរបស់
# ផណាធានពលរដ្ឋរុងរឿង



# ទំនួលខុសត្រូវ
# សង្គមរបស់អាយភីអា

អាយភីអា តែងតែខិតខំធ្វើការរួមចំណែកជាវិជ្ជមានដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងបរិស្ថានរបស់ប្រទេស។ ឆ្ពោះទៅរកទីបញ្ចប់នេះ អាយភីអា បង្កើតយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីបំពេញការទទួលខុសត្រូវចំពោះបុគ្គលិក អតិថិជន សង្គម និងបរិស្ថាន។



## ទំនួលខុសត្រូវចំពោះបុគ្គលិក

សុខុមាលភាព និងការអភិវឌ្ឍន៍របស់បុគ្គលិក គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពចម្បងរបស់ អាយភីអា។ នោះហើយជាមូលហេតុដែលអាយភីអាផ្តល់ឱកាសជានិច្ចសម្រាប់ការរីកចម្រើនវង្វាន់ និងជំនួយសម្រាប់បុគ្គលិកដែលសមនឹងទទួលបាន។ ជារៀងរាល់ឆ្នាំអាយភីអា បានផ្តល់ការតំរង់ទិសដល់បុគ្គលិក ការបណ្តុះបណ្តាលខាងក្នុង ការបណ្តុះបណ្តាលខាងក្រៅ និងការចូលរួមសិក្ខាសាលាផងដែរ។



## ទំនួលខុសត្រូវចំពោះអតិថិជន

អាយភីអា យកចិត្តទុកដាក់ចំពោះសុខុមាលភាពហិរញ្ញវត្ថុរបស់អតិថិជន ហើយតែងតែបំពេញតម្រូវការរបស់ពួកគេ។ អាយភីអា ប្តេជ្ញាចិត្តចំពោះការអនុវត្ត និងការការពារអ្នកប្រើប្រាស់ដោយយុត្តិធម៌។ អាយភីអា បាននឹងកំពុងត្រៀមខ្លួនបំពេញនូវកាតព្វកិច្ចដើម្បីទទួលបានវិញ្ញាបនប័ត្រនៃគោលការណ៍ការពារអតិថិជន ( CPP ) ពី CP pathway។



## ទំនួលខុសត្រូវចំពោះសង្គម និងបរិស្ថាន

អាយភីអា ដឹងយ៉ាងច្បាស់ និងរស់នៅតាមទំនួលខុសត្រូវរបស់ខ្លួន ដើម្បីនាំមកនូវផលវិជ្ជមានដល់សង្គម និងបរិស្ថាន។ បច្ចុប្បន្ននេះគ្រឹះស្ថាន មិនមានវិធានការណាមួយដើម្បីវាយតម្លៃពីផលប៉ះពាល់សង្គម និងបរិស្ថានរបស់ខ្លួនទេ តែទោះជាយ៉ាងណាក៏ដោយ យើងព្យាយាមលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធ ឱ្យយកចិត្តទុកដាក់យ៉ាងខ្លាំងលើបរិស្ថាន និងមានគំនិតសន្សំសំចៃចំពោះការប្រើប្រាស់ទឹក ភ្លើង ប្រេង ដូចជាការកាត់បន្ថយការប្រើប្រាស់ក្រដាស និងសន្សំសំចៃទឹក និងអគ្គិសនីជាដើម។ ចំពោះកាតព្វកិច្ចរបស់យើងចំពោះសាធារណៈជន អាយភីអា តែងតែធ្វើការបរិច្ចាគសម្រាប់ការសង្គ្រោះជាតិ និងឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនក្នុងគ្រាលំបាករបស់ពួកគេ។ ប្រធានក្រុមប្រឹក្សាភិបាលរបស់អាយភីអា តែងតែចូលរួមជួយសង្គម ជាពិសេសកសិករ ហើយបានកសាងវប្បធម៌សម្រាប់អាយភីអា ក្នុងការផ្តល់ជំនួយ មិនថាតូចប៉ុណ្ណាក៏ដោយ អាយភីអានឹងតែងតែជាចំណែកមួយជួយសង្គមនៅពេលសង្គមត្រូវការ។

នៅចុងឆ្នាំ២០២៣ អាយភីអា បានចាប់ផ្តើមធ្វើការតាមដានការប្រើប្រាស់ធនធានដូចខាងក្រោម៖

Electricity Consumptions:



**in KWH: 77,489 KWH**
**in USD: 14,690.09 USD**

Fuel Consumptions:



**in Litter: 14,126.48 L**
**in USD: 15,073.89 USD**

Water Consumptions:



**in Cubic meter: 1,475.00 M3**
**in USD: 704.58 USD**

Paper Usages:



**In small box: 63 boxes**
**In USD:  1,041.18 USD**

# របាយការណ៍
## បង់ពន្ធ

| សូចនាករ | ($) ២០២៣ | ($) ២០២២ | ($) ២០២១ | ($) ២០២០ |
|---|---|---|---|---|
| ពន្ធប៉ាតង់ | ៣,៦៧១.៩៧ | ៣,៦៤៣.៤៣ | ៣,៦៨១.៨៩ | ៣,៦៧៩.១៨ |
| ពន្ធលើស្លាកសញ្ញា | ២,៧៩៧.៧០ | ២,២៩២.៧៦ | ៤២៦.៨៨ | ៤៨៥.៧៤ |
| ពន្ធលើមធ្យោបាយដឹកជញ្ជូន | ៩៧.៩២ | ២,៣០៧.០៩ | ២,២៩២.៧៦ | ៤២៦.៨៨ |
| ពន្ធលើប្រាក់បៀវត្សរ៍ | ២០,៩៩២.០០ | ៩៧.១៦ | ៩៨.១៨ | ៩៨.៨៩ |
| ប្រាក់រំលស់ពន្ធលើប្រាក់ចំណេញ | ១៣,៨៣២.៧៦ | ១៨,៦៨៩.៤៧ | ១៣,៦៧៨.១៧ | ១៣,២៤៣.៤១ |
| ពន្ធកាត់ទុកលើថ្លៃឈ្នួលអចលនទ្រព្យ | ៨,០៣២.១៧ | ១៤,៨៨៥.៣១ | ១៤,១៨៦.៧០ | ១៣,៦៧៨.១៧ |
| ពន្ធកាត់ទុកលើសេវាកម្ម (និវាសនជន) | ១០,៥៥៣.៥៤ | ៧,៤៤៨.៦២ | ៨,៣៣៤.៩៨ | ៩,៧៧៩.២៧ |
| ពន្ធកាត់ទុកលើថ្លៃសេវា (អនិវាសនជន) | ៣៣៤.៥៩ | ១០,៥៤៥.៣៧ | ១៥,៦២១.៦៨ | ១១,៤១៧.០៦ |
| ពន្ធកាត់ទុកលើការប្រាក់ (និវាសនជន) | - | ១,៨៣៧.៤៧ | ១,៧៩៨.៨៥ | ១,៧៦៨.២៦ |
| ពន្ធកាត់ទុកលើការប្រាក់ (អនិវាសនជន) | - | - | - | - |
| ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ | ២៨,០៣១.០១ | ៤,២០៦.៨៦ | ៣,២៩៤.១២ | ៤៨,២១៩.៥០ |
| ពន្ធប្រថាប់ត្រា | - | - | - | - |
| ពន្ធបន្ថែម | - | ២៤២.៨៤ | ៨,០៧៦.៩៣ | - |

# សម្រង់របាយការណ៍
## សវនកម្មហិរញ្ញវត្ថុឆ្នាំ២០២៣



# របាយការណ៍
# របស់ក្រុមប្រឹក្សាភិបាល

**ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ឥណទានពលរដ្ឋរុងរឿង អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។**

## ព័ត៌មានពីក្រុមហ៊ុន

ឥណទានពលរដ្ឋរុងរឿង អិលធីឌី (ហៅកាត់ថា "IPR" ឬ "ក្រុមហ៊ុន") ដែលពីមុនត្រូវបានគេស្គាល់ថាជាអង្គភាពឥណទានរបស់សហព័ន្ធស្រូវអង្ករកម្ពុជា។ ក្រុមហ៊ុនបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមលេខចុះបញ្ជី ០០០១៧៦៤៣ ដែលចេញដោយក្រសួងពាណិជ្ជកម្ម ("MOC") នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ ហើយបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ("NBC") ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មជាស្ថាប័នមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុជាអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ ។

ការិយាល័យចុះបញ្ជីដើមរបស់ក្រុមហ៊ុន មានទីតាំងនៅផ្ទះលេខ ៧៧៩A ផ្លូវកម្ពុជាក្រោម (១២៨) សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ក្រោយមក ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុនត្រូវបានប្តូរទៅផ្ទះលេខ ៧២B ផ្លូវលេខ៣១៧ ភូមិ៦ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២។ វិសោធនកម្មលើលក្ខន្តិកៈក្រុមហ៊ុន និងវិញ្ញាបនបត្រត្រូវបានអនុម័តដោយ MOC នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២២។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុនមាននិយោជិតចំនួន ៧៧ នាក់ (ឆ្នាំ២០២២៖ មានចំនួន ៧៦ នាក់)។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាឥណទាន ដើម្បីលើកកំពស់កម្រិតជីវភាពរបស់អតិថិជនទាក់ទងនឹងការអភិវឌ្ឍន៍ជនបទ។ សេវាឥណទានប្រភេទនេះធ្វើការផ្តល់ជូនដល់អតិថិជននៅតាមទីតាំងដែលស្ថិតនៅ ការិយាល័យកណ្តាលក្នុង រាជធានីភ្នំពេញ និងសាខានៅតាមបណ្តាលខេត្តផ្សេងៗទៀតមានដូចជាទីតាំងដែលស្ថិតនៅក្នុងខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិអាជីវកម្មរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងស្ថានភាពអាជីវកម្មរបស់ក្រុមហ៊ុននាកាលបរិច្ឆេទនោះ ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ។

## ភាគលាភ

ក្រុមប្រឹក្សាភិបាលពុំបានផ្តល់អនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នេះឡើយ។

## ក្រុមប្រឹក្សាភិបាល

សមាជិករបស់ក្រុមប្រឹក្សាភិបាលក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង |
| --- | --- |
| លោកឧកញ៉ា ភួ ពុយ | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Hsu Ming Yee | អភិបាល |
| លោក ស្រី ប៉ុក នីរីល័យ | អភិបាល |
| លោក ប៊ិច សានី | អភិបាល |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនស្នងការគណនេយ្យ ហ្វ្រេន សនថុន (ខេមបូឌា) លីមីធីត។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ មិនមានកិច្ចព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនជាភាគីក្នុងគោលបំណងផ្តល់លទ្ធភាពដល់អភិបាលអោយទទួលបានអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសកម្មភាពសាជីវកម្មផ្សេងៗទៀតឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទនេះ ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលរួមបញ្ចូលនៅក្នុងសមតុល្យនៃប្រាក់បំណាច់ដែលទទួលបាន ឬដល់ពេលកំណត់ និងអាចទទួលបានដោយអភិបាល ដូចដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ) ក្រោមហេតុផលនៃកិច្ចសន្យាដែលធ្វើឡើងដោយក្រុមហ៊ុន ឬសាជីវកម្មដែលពាក់ព័ន្ធជាមួយក្រុមហ៊ុនដែលជាសមាជិកនៃក្រុមប្រឹក្សាភិបាល ឬជាមួយក្រុមហ៊ុនដែលអភិបាលមានផលប្រយោជន៍ជាសារវន្តនៃផ្នែកហិរញ្ញវត្ថុ ក្រៅពីប្រតិបត្តិការដែលមានភ្ជាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការអះអាងថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយផ្តល់នូវគ្រប់ទិដ្ឋភាព និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

១. អនុម័តនូវគោលនយោបាយគណនេយ្យដែលអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម ("CIFRS for SMEs") និងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

២. គោរពតាមតម្រូវការលាតត្រដាងនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយពីតម្រូវការទាំងនោះ ក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវ ត្រូវប្រាកដថាការប្រាសចាកទាំងនេះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

៣. រក្សាទុកកំណត់ត្រាគណនេយ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនអាចសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នាពេលអនាគតបន្តទៀតបាន និង

៥. ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព និងចូលរួមលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថារាល់ការសម្រេចចិត្ត និង/ឬសេចក្តីណែនាំនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានាដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល អមមកជាមួយរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ ព្រមទាំងកំណត់សម្គាល់នានា ត្រូវបានរៀបចំឡើងយ៉ាងសមស្រប និងបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។




**លោកឧកញ៉ា ភួ ពុយ**
**ប្រធានក្រុមប្រឹក្សាភិបាល**

**រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤**
**នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖**

# របាយការណ៍
# របស់សវនករឯករាជ្យ

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង (កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

## ជូនចំពោះភាគហ៊ុនិក របស់ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី (ហៅកាត់ "ក្រុមហ៊ុន") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំង សេចក្ដីសង្ខេបទៅលើគោលការណ៍គណនេយ្យសំខាន់ៗ និងសេចក្ដីពន្យល់ព័ត៌មានផ្សេងទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបានបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវជាសារវន្តលើស្ថានភាព ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម ("CIFRS for SMEs") រួមជាមួយនិងសេចក្ដីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

### មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារ អន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ "ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ ហិរញ្ញវត្ថុ" នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុនដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែល ពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាម តម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

### ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រង មានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន របាយការណ៍របស់ ក្រុមប្រឹក្សាភិបាល ក៏ប៉ុន្តែ មិនរាប់បញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំ ដែលទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករ និង របាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងទុកថានឹងរៀបចំរួចរាល់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្ដប់ទៅលើព័ត៌មានផ្សេងៗទេ។ យើងខ្ញុំមិនផ្តល់សេចក្ដីសន្និដ្ឋានក្នុង ទម្រង់ពីការធានាបែបណាមួយឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំ ដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្ត ឬទេ។

ប្រសិនបើ យោងតាមការងារដែលយើងបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថា បើមានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មាន ផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗ នេះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មានទំនួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម រួមជាមួយនិងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងការទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រង កំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ការលាតត្រដាង និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយ ពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែល រួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ( “CISAs” )នឹងតែងតែរកឃើញនូវការ រាយការណ៍ខុសជាសារវន្តដែលកើតមានឡើងនោះឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនារៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជា មូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវ នឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយ ស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

Grant Thornton

ហ្គ្រេន ថនតុន (ខេមបូឌា) លីមីតិត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤

# ស្ថានភាពហិរញ្ញវត្ថុ

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៣.២) | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ៣.២) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៥ | **១.០០៥.៧៧៤** | **១.១០៨.៥៨៧** | ៤២១.៥៩០ | ១.៧៣៥.៦៨៦ |
| ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ | ៧ | **១៥៤.៤៣២** | **៦៣៥.៨៥៥** | ១៥៤.៤៣២ | ៦៣៥.៧៩៧ |
| ឥណទានផ្តល់ជូនអតិថិជន - សុទ្ធ | ៧ | **៦.៣៦៤.៤៩០** | **២៥.៩៩៩.៩៤២** | ៦.៧៧៦.៣៨៧ | ២៧.៨៩៨.៣៨៥ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | **៩២.៧៨៥** | **៣៧៩.០២៧** | ២៦.១៥៥ | ១០៧.៦៨០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | **៤១.១២០** | **១៦៧.៩៧៥** | ៣៣.១៤២ | ១៣៦.៤៤៦ |
| ទ្រព្យសកម្មពន្ធពន្យារ -សុទ្ធ | ១១(គ) | **១៥.០០៣** | **៦១.២៨៧** | ៦១.៩៤៥ | ២៥៥.០២៨ |
| **ទ្រព្យសកម្មសរុប** | | **៧.៦៧៣.៦០៤** | **៣១.៣៤៦.៦៧៣** | ៧.៤៧៣.៦៥១ | ៣០.៧៦៩.០២២ |
| **មូលធន និងបំណុល** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | ១០ | **១២.២០២** | **៤៩.៨៤៦** | ១២.១២០ | ៤៩.៨៩៩ |
| បំណុលពន្ធលើប្រាក់ចំណូល | ១១(ឃ) | **៥០.១០៨** | **២០៤.៦៩១** | ៨៣.០៥២ | ៣៤១.៩២៥ |
| **បំណុលសរុប** | | **៦២.៣១០** | **២៥៤.៥៣៧** | ៩៥.១៧២ | ៣៩១.៨២៤ |
| **មូលធន** | | | | | |
| ដើមទុន | ១២ | **៣.០៨៨.៦៤៥** | **១២.៤៦៨.៨៦០** | ៣.០៨៨.៦៤៥ | ១២.៤៦៨.៨៦០ |
| ប្រាក់ចំណេញរក្សាទុក | | **៤.៤៤៩.៣២៧** | **១៧.៩៩១.៦០៧** | ៤.២៨៩.៨៣៤ | ១៧.៣៣៦.០៩១ |
| ទុកបម្រុងតាមបទប្បញ្ញត្តិ | ១៣ | **៧៣.៣២២** | **៣០១.៣៥៣** | - | - |
| ការប្តូររូបិយប័ណ្ណបម្រុងទុក | | - | **៣៣០.៣១៦** | - | ៥៧២.២៤៧ |
| **មូលធនសរុប** | | **៧.៦១១.២៩៤** | **៣១.០៩២.១៣៦** | ៧.៣៧៨.៤៧៩ | ៣០.៣៧៧.១៩៨ |
| **មូលធន និងបំណុលសរុប** | | ៧.៦៧៣.៦០៤ | ៣១.៣៤៦.៦៧៣ | ៧.៤៧៣.៦៥១ | ៣០.៧៦៩.០២២ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍

# ចំណូលលម្អិត

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) |
| ចំណូលប្រតិបត្តិការ | | | | | |
| ចំណូលការប្រាក់ | ១៤ | **១.២៩០.២៦០** | **៥.៣០២.៩៦៩** | ១.៣៧១.៩៦៣ | ៥.៦០៧.២១៣ |
| ចំណាយការប្រាក់ | ១៥ | - | - | (១៧.៦៤៧) | (៧២.១២៣) |
| **ចំណូលការប្រាក់សុទ្ធ** | | **១.២៩០.២៦០** | **៥.៣០២.៩៦៩** | ១.៣៥៤.៣១៦ | ៥.៥៣៥.០៩០ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ១៦ | **១០៥.២៩៧** | **៤៣២.៧៧១** | ១១៦.៥៦៦ | ៤៧៦.៤០៥ |
| **ចំណូលប្រតិបត្តិការសុទ្ធ** | | **១.៣៩៥.៥៥៧** | **៥.៧៣៥.៧៤០** | ១.៤៧០.៨៨២ | ៦.០១១.៤៩៥ |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ១៧ | **(៨៦៣.៩២៣)** | **(៣.៥៥០.៧២៤)** | (៩០១.៧៦០) | (៣.៦៨៥.៤៩៣) |
| សំវិធានធនលើការខាតបង់ឱនភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ | | **(១៨១.៨០៥)** | **(៧៤៧.២១៩)** | (៩១.២០៣) | (៣៧២.៧៤៧) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | **៣៤៩.៨២៩** | **១.៤៣៧.៧៩៧** | ៤៧៧.៩១៩ | ១.៩៥៣.២៥៥ |
| ចំណាយពន្ធលើប្រាក់ចំណូល | ១១(ក) | **(១១៧.០១៤)** | **(៤៨០.៩២៨)** | (១៣៩១០៩) | (៥៦៨.៥៣៨) |
| **ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | **២៣២.៨១៥** | **៩៥៦.៨៦៩** | ៣៣៨.៦១០ | ១.៣៨៤.៧១៧ |
| **ចំណូលលម្អិតផ្សេងៗ** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **(២៤១.៩៣១)** | - | ៣២០.៦៦៩ |
| **ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | **២៣២.៨១៥** | **១.៧០៥.៣៨៦** | ៣៣៨.៨១០ | ១.៧០៥.៣៨៦ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) |
| **សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ៣.០៨៨.៦៤៥ | ១២.៤៦៨.៨៦០ | ៤.២៨៩.៨៣៤ | ១៧.៣៣៦.០៩១ | - | - | | ៥៧២.២៤៧ | ៧.៣៧៨.៤៧៩ | ៣០.៣៧៧.១៩៨ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | ២៣២.៨១៥ | ៩៥៦.៨៦៩ | - | - | | - | ២៣២.៨១៥ | ១.៣៨៤.៧១៧ |
| **ទុនបម្រុងតាមបទប្បញ្ញត្តិ** | - | - | (៧៣.៣២២) | (៣០១.៣៥៣) | ៧៣.៣២២ | ៣០១.៣៥៣ | | - | - | - |
| **លម្អៀងពីការប្តូររូបិយប័ណ្ណ** | - | - | - | - | - | - | | (២៤១.៩៣១) | - | (២៤១.៩៣១) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | ៣.០៨៨.៦៤៥ | ១២.៤៦៨.៨៦០ | ៤.៤៤៩.៣២៧ | ១៧.៩៩១.៦០៧ | ៧៣.៣២២ | ៣០១.៣៥៣ | | ៣៣០.៣១៦ | ៧.៦១១.២៩៤ | ៣១.០៩២.១៣៦ |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៣.០៨៨.៦៤៥ | ១២.៤៦៨.៨៦០ | ៤.៥៥១.០២៤ | ១៨.៤០៣.៥៧៤ | - | - | | ២៥១.៥៧៨ | ៧.៦៣៩.៦៦៩ | ៣១.១២៤.០១២ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | ៣៣៨.៨១០ | ១.៣៨៤.៧១៧ | - | - | | - | ៣៣៨.៨១០ | ១.៣៨៤.៧១៧ |
| ការទូទាត់ភាគលាភ | - | - | (៦០០.០០០) | (២.៤៥២.២០០) | - | - | | - | (៦០០.០០០) | (២.៤៥២.២០០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | | ៣២០.៦៦៩ | - | ៣២០.៦៦៩ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៣.០៨៨.៦៤៥ | ១២.៤៦៨.៨៦០ | ៤.២៨៩.៨៣៤ | ១៧.៣៣៦.០៩១ | - | - | | ៥៧២.២៤៧ | ៧.៣៧៨.៤៧៩ | ៣០.៣៧៧.១៩៨ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍

# លំហូរសាច់ប្រាក់

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | **៣៤៩.៨២៩** | **១.៤៣៧.៧៩៧** | ៤៧៧.៩១៩ | ១.៩៥៣.២៤៥ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| ចំណូលការប្រាក់ | ១៤ | **(១.២៩០.២៦០)** | **(៥.៣០២.៩៦៩)** | (១.៣៧១.៩៦៣) | (៥.៦០៧.២១៣) |
| ចំណាយការប្រាក់ | ១៥ | - | - | ១៧.៦៤៧ | ៧២.១២៣ |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេសមិនបានទទួលស្គាល់ | ១៦ | **(២៤.៦៩៧)** | **(១០១.៥០៥)** | - | - |
| រំលស់លើទ្រព្យសកម្មរូបី និងអរូបី | ៩ | **១៤.៨៥២** | **៦១.០៤២** | ១២.៧៨៣ | ៥២.២៤២ |
| ការខាតបង់ឱនភាពតម្លៃលើសំវិធានធននៃទ្រព្យសកម្មហិរញ្ញវត្ថុ | | **១៨១.៨០៥** | **៧៤៧.២១៩** | ៩១.២០៣ | ៣៧២.៧៤៧ |
| **ខាតប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល បម្រែបម្រួលទុនបង្វិលសុទ្ធ** | | **(៧៦៨.៤៧១)** | **(៣.១៥៨.៤១៦)** | (៧៧២.៤១១) | (៣.១៥៦.៨៥៦) |
| ឥណទានផ្តល់ជូនអតិថិជន | | **២៤៣.៤៣៩** | **១.០០០.៥៣៤** | (២៩១.៩៥២) | (១.១៩៣.២០៨) |
| ទ្រព្យសកម្មផ្សេងៗ | | **(៦៦.៦៣០)** | **(២៧៣.៨៤៩)** | ៤.៦០៥ | ១៨.៨២១ |
| បំណុលផ្សេងៗ | | **៨២** | **៣៣៧** | (៦.៨៤៤) | (២៧.៩៧១) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | **(៥៩១.៥៨០)** | **(២.៤៣១.៣៩៤)** | (១.០៦៦.៦០២) | (៤.៣៥៩.២១៤) |
| ការប្រាក់ដែលបានទទួល | | **១.៣០១.៦១០** | **៥.៣៤៩.៦១៧** | ១.៣៥៩.៤៣០ | ៥.៥៥៥.៩៩០ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | ១១(ឃ) | **(១០៣.០១៦)** | **(៤២៣.៣៩៦)** | (៨០.០៥៥) | (៣២៧.១៨៥) |
| **សាច់ប្រាក់សុទ្ធបានពី/បានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | **៦០៧.០១៤** | **២.៤៩៤.៨២៧** | ២១២.៧៧៣ | ៨៦៩.៥៩១ |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | **(២២.៨៣០)** | **(៩៣.៨៣១)** | (៩.៨៧៤) | (៤០.៣៥៣) |
| ចំណូលបានពីប្រាក់បញ្ញើតាមកាលកំណត់ | | - | - | ១២.៥០០ | ៥១.០៨៨ |
| **សាច់ប្រាក់សុទ្ធបានពី/បានប្រើក្នុងសកម្មភាពវិនិយោគ** | | **(២២.៨៣០)** | **(៩៣.៨៣១)** | ២.៦២៦ | ១០.៧៣៥ |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| ការប្រាក់បានបង់ | | - | - | (១៩.៥២២) | (៧៩.៧៨៦) |
| ភាគលាភបានបង់ | | - | - | (៦០០.០០០) | (២.៤៥២.២០០) |
| ការទូទាត់សងចំណែកនៃប្រាក់កម្ចីដើម | | - | - | (៣០០.០០០) | (១.២២៦.១០០) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញវត្ថុ** | | - | - | (៩១៩.៥២២) | (៣.៧៥៨.០៨៦) |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **៥៨៤.១៨៤** | **២.៤០០.៩៩៦** | (៧០៤.១២៣) | (២.៨៧៧.៧៦០) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមការិយបរិច្ឆេទ** | | **៤២១.៥៩០** | **១.៧៣៥.៦៨៦** | ១.១២៥.៧១៣ | ៤.៥៨៦.១៥៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **(២៨.០៩៥)** | - | ២៧.២៩១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ** | | **១.០០៥.៧៧៤** | **៤.១០៨.៥៨៧** | ៤២១.៥៩០ | ១.៧៣៥.៦៨៦ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# ព័ត៌មានទំនាក់ទំនង



# បណ្ដាញសាខា




## ភ្នំពេញ

ការិយាល័យកណ្ដាល៖ ផ្ទះលេខ ៧២B, ផ្លូវលេខ ៣១៧, ភូមិ០៦, សង្កាត់បឹងកក់០២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

## ខេត្តបន្ទាយមានជ័យ

សាខាបន្ទាយមានជ័យ

## ខេត្តតាកែវ

សាខាតាកែវ

## ខេត្តពោធិ៍សាត់

សាខាពោធិ៍សាត់

## ខេត្តបាត់ដំបង

សាខាភ្នំព្រឹក
សាខាបាត់ដំបង
សាខាសំពៅលូន
សាខាសំឡូត

# អាសយដ្ឋានសាខាខេត្ត

## ភ្នំពេញ

### ការិយាល័យកណ្ដាល

អាសយដ្ឋាន៖ អគារលេខ៧២ បេ ផ្លូវលេខ ៣១៧ ភូមិ៦ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា។
ទូរសព្ទ៖ ០២៣ ៩៩០ ២៣៧ / ០៧០ ៩៩៩ ៧៣៩
អ៊ីម៉ែល៖ info@iprmfi.com | គេហទំព័រ៖ www.iprmfi.com

## ខេត្តតាកែវ

### សាខាតាកែវ

អាសយដ្ឋាន៖ ភូមិខ្សឹង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
ទូរសព្ទ៖ ០៧០ ៩៩៩ ២៣៣ / ០៧០ ៩៩៩ ២៣៥
អ៊ីម៉ែល៖ bm002@iprmfi.com

## ខេត្តពោធិ៍សាត់

### សាខាពោធិ៍សាត់

អាសយដ្ឋាន៖ ភូមិខ្នាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់។
ទូរសព្ទ៖ ០៧០ ៩៩៩ ៤៩៥ / ០៧០ ៩៩៩ ៤៩១
អ៊ីម៉ែល៖ bm005@iprmfi.com

## ខេត្តបាត់ដំបង

### សាខាភ្នំព្រឹក

អាសយដ្ឋាន៖ ភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។
ទូរសព្ទ៖ ០៧០ ៩៩៩ ៣២៣ / ០៧០ ៩៩៩ ៣២៥
អ៊ីម៉ែល៖bm003@iprmfi.com

### សាខាបាត់ដំបង

អាសយដ្ឋាន៖ ភូមិអញ្ចាញ សង្កាត់អូរចារ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។
ទូរសព្ទ៖ ០៧០ ៩៩៩ ៦៩៤ / ០៧០ ៩៩៩ ៦៩២
អ៊ីម៉ែល៖ bm007@iprmfi.com

### សាខាសំពៅលូន

អាសយដ្ឋាន៖ ភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។
ទូរសព្ទ៖ ០៧០ ៩៩៩ ៣២៦ / ០៧០ ៩៩៩ ៣៤៧
អ៊ីម៉ែល៖ bm007@iprmfi.com

### សាខាសំឡូត

អាសយដ្ឋាន៖ ភូមិតាសាញ់ខាងជើង ឃុំតាសាញ់ ស្រុកសំឡូត ខេត្តបាត់ដំបង។
ទូរសព្ទ៖ ០៧០ ៩៩៩ ៧៣៤ / ០៧០ ៩៩៩ ៧២៦
អ៊ីម៉ែល៖ bm010@iprmfi.com

## ខេត្តបន្ទាយមានជ័យ

### សាខាបន្ទាយមានជ័យ

អាសយដ្ឋាន៖ ភូមិអូរស្ងួត ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។
ទូរសព្ទ៖ ០៧០ ៩៩៩ ៤៧៨ / ០៧០ ៩៩៩ ៧៤៩
អ៊ីម៉ែល៖ bm004@iprmfi.com




ការិយាល័យកណ្តាលៈ អគារលេខ ៧២ បេ ផ្លូវលេខ ៣១៧ ភូមិ៦ សង្កាត់បឹងកក់២
ខណ្ឌទួលគោក រាជធានីភ្នំពេញ។
Tel: 023 990 237 / 070 999 739 / E-mail: info@iprmfi.com / Website: www.iprmfi.com